ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ
Khmer Movement For Democracy
Organize the Movement * Educate the Public * Mobilize the People

08 មករា, 2025

**KMD មានក្តីរន្ធត់ចំពោះការធ្វើឃាតឯកឧត្តម លឹម គឹមយ៉ា យ៉ាងព្រៃផ្សៃ**

ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ (KMD) មានការសោកស្តាយជាខ្លាំងចំពោះការធ្វើឃាតដ៏ព្រៃផ្សៃ និងអមនុស្សធម៌ ទៅលើឯកឧត្តម លឹម គឹមយ៉ា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ មកពីខេត្តកំពង់ធំ ដែលបានកើតឡើងទាំងថ្ងៃត្រង់នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០២៥។

ឃាតកម្មឈាមត្រជាក់នេះ បង្ហាញពីការមិនគោរពជីវិតមនុស្ស និងនីតិរដ្ឋ។ ការវាយប្រហារដៃឆៅនេះបង្ហាញពីអារម្មណ៍សុខស្រួលនៃនិទណ្ឌភាព ដែលទំនងជាកើតចេញពីការគំរាមកំហែងថ្មីៗដោយរបបកម្ពុជាប្រឆាំងនឹងលោក លឹម គឹមយ៉ា បន្ទាប់ពីការរិះគន់ជាសាធារណៈរបស់គាត់។

ការធ្វើឃាតនេះ បានបន្ទរនូវក្តីកង្វល់ដែលលើកឡើងម្តងហើយម្តងទៀតដោយចលនាខ្មែរដើម្បីប្រជាធិបតេយ្យ (KMD) ទាក់ទងនឹងយុទ្ធនាការគាបសង្កត់ឆ្លងដែនរបស់របបកម្ពុជាចាប់តាំងពីពាក់កណ្តាលឆ្នាំមុន។ KMD បានចងក្រងជាឯកសារ និងថ្កោលទោសរហូតមកនូវករណីជាច្រើននៃការឃាយឃី ការបំភិតបំភ័យ និងអំពើហឹង្សាលើអ្នកប្រឆាំង សកម្មជន និងអ្នកសារព័ត៌មានដែលរស់នៅបរទេស។ គំរូនៃនិទណ្ឌភាពនេះពង្រឹងរបបកម្ពុជាសព្វថ្ងៃ និងបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់អាយុជីវិត និងសេរីភាពនៃជនភៀសខ្លួនកម្ពុជា។

គោលបំណងនៃការវាយប្រហារទាំងនេះ គឺមិនត្រឹមតែបង្កើតបរិយាកាសនៃការភ័យខ្លាច និងការបំភិតបំភ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលុបបំបាត់ការគិតបែបរិះគន់កែលម្អរបស់ពលរដ្ឋខ្មែរដែលកំពុងរស់នៅក្នុងប្រទេស និងនិរទេសនៅទូទាំងពិភពលោក ពីទីក្រុងបាងកក ដល់ទីក្រុងប្រ៊ុចសែល ពីមែលបិន ទៅប៉ារីស ពីឡូសអង់ចាឡែស ទៅម៉ុងត្រេអាល់។

KMD ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើដ៏សាហាវយង់ឃ្នងនេះថាជាការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងការគំរាមកំហែងដោយផ្ទាល់ដល់ជីវិតផ្ទាល់ខ្លួន និងសេរីភាពនយោបាយ។ យើងជំរុញឱ្យអាជ្ញាធរថៃធ្វើការស៊ើបអង្កេតឱ្យបានលឿន ហ្មត់ចត់ និងមិនលម្អៀងលើឃាតកម្មនេះ ហើយនាំជនល្មើសមកកាត់ទោស។

យើងខ្ញុំសូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំបំផុតចំពោះក្រុមគ្រួសារ និងមនុស្សជាទីស្រលាញ់របស់ ឯកឧត្តម លឹម គឹមយ៉ា។

111 Fitchburg Rd, Ayer, MA 01432
contact@khmermovementfordemocracy.org
Khmermovementfordemocracy.org
+1 702 808 0337

N-O